ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។
កណ្តាល. ថ្ងៃទី០៩ ខែ 6 ឆ្នាំ ២០14
ក្រឡាបញ្ជី
[redacted]

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨២១អក
ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២
សាលក្រមលេខ៖ ១៨ (ឆ.វ.ន)
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាលនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ៩ ព្រឹកដោយមានសមាសភាពដូចតទៅ:

### <u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តកណ្តាល
លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងខេត្តកណ្តាល
លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨២១ អក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១២ ដែលមានជនជាប់ចោទ៖

-ឈ្មោះ: [redacted] គឹមឡុង ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិកំពង់កុង ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ: [redacted] (រស់) ម្តាយឈ្មោះ: [redacted] (រស់) ប្រពន្ធឈ្មោះ: [redacted] មានកូន០២នាក់។

ត្រូវបានចោទប្រកាន់ពីបទ៖ អំពើលួច(មានស្ថានទម្ងន់) ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារជនជាប់ចោទលោកស្រី ច័ន្ទ រាសីភ័ក្ត្រ។

### ដំណើររឿងហេតុមានដូចតទៅ

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង១៨ និង៣០នាទី នៅមុខផ្ទះលេខ២២៦ ដែលមានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅខេត្តកណ្តាល មានជនសង្ស័យចំនួនពីរឈ្មោះ:



Scanned by CamScanner

គីមឡុង និងឈ្មោះ [redacted]តូ បានជិះម៉ូតូម៉ាកSuzuki Smash V ពណ៌ខ្មៅ ស៊េរី ឆ្នាំ២០១២បានមកឈប់ម៉ូតូ និងធ្វើការដណ្តើមកាបូបរបស់ឈ្មោះ [redacted] សារិន ភេទស្រី អាយុ ៥២ ឆ្នាំ តែជនរងគ្រោះពុំព្រមឲ្យ ពេលនោះជនសង្ស័យឈ្មោះ[redacted] តូ បានដកកាំភ្លើងខ្លីម៉ាក K ៥៩ បាញ់ចំនួនពីរគ្រាប់ត្រូវជនរងគ្រោះ បន្ទាប់មកជនរងគ្រោះបានបោះកាបូបចូលក្នុងរបងផ្ទះ ហើយប្តីរបស់ជនរងគ្រោះបានស្រែកថាចោរៗ រួចបានរត់ចូលទៅប្រតាយប្រតប់ជាមួយជនសង្ស័យឈ្មោះ[redacted] តូ ដែលកាន់កាំភ្លើងបណ្តាលឲ្យផ្ទុះមួយគ្រាប់ទៀតត្រូវបក្សពួករបស់ខ្លួនឈ្មោះ [redacted]គីមឡុង ដួលទៅដី ពេលលឺដូច្នេះមានអ្នកជិតខាងម្នាក់ឈ្មោះ [redacted]លន បានស្ទុះចូលមកប្រតាយប្រតប់ជាមួយជនសង្ស័យឈ្មោះ [redacted] តូ ដែលបណ្តាលឲ្យផ្ទុះកាំភ្លើងចំនួនពីរគ្រាប់ទៀត បន្ទាប់មកឈ្មោះ[redacted] លន បានចាប់កាំភ្លើងតែរបូតសល់តែគំរប់ចលនា រីឯតួកាំភ្លើង ជនសង្ស័យឈ្មោះ [redacted] តូ បានយកតាមខ្លួន និងរត់គេចភ្លាមៗតែម្តង នៅសល់តែជនសង្ស័យឈ្មោះ [redacted] គីមឡុង ដែលរងរបួសដោយសារគ្រាប់កាំភ្លើងនៅកន្លែងកើតហេតុ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៥២ ដកសព ចុះថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាដំណោះស្រាយលេខៈ ២៤០ ដកដស ចុះថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

បានឃើញ ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]គីមឡុង ហៅ ឡុង បានឆ្លើយថាៈ ខ្លួនមិនដែលប្រព្រឹត្តបទល្មើសពីមុនមកទេ។ កាលពីថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១២ វេលាម៉ោងប្រហែល បួនរសៀល ឈ្មោះ [redacted] តូ បានមកបបួលរូបខ្លួនឲ្យទៅទារលុយគេនៅក្រុងតាខ្មៅ ហើយខ្លួនក៏បានយកម៉ូតូរបស់ឈ្មោះ [redacted] តូ ម៉ាកស៊ុយស្ហ៊ីស្មាក់វី ស៊េរីឆ្នាំ២០១១ ពណ៌ខ្មៅ មានស្លាកលេខៈ ភ្នំពេញ ១Bl ៤៧៤៤ ឱបឈ្មោះ[redacted] តូ។ លុះពេលមកដល់ផ្ទះជនរងគ្រោះ ឈ្មោះ[redacted] តូ បានចុះទៅនិយាយជាមួយជនរងគ្រោះ ក៏មានទំនាស់គ្នា និងប្រទាញប្រទង់គ្នា រួចខ្លួនក៏ចូលជួយឃាត់ ស្រាប់តែឈ្មោះ [redacted]តូ បានដកកាំភ្លើងបាញ់បួនទៅប្រាំគ្រាប់ បណ្តាលឲ្យត្រូវខ្លួនចំត្រគៀកខាងឆ្វេងមួយគ្រាប់ដួលអុកគូថ ចំណែកឈ្មោះ[redacted] តូ បានរត់គេចខ្លួនបាត់។ ខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសទេ។ ខ្លួនស្នើសុំដល់តុលាការមេត្តាឱ្យជួយលើកលែងទោសឱ្យខ្លួន។

-អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សារិន បានបញ្ជាក់ថាៈ កាលពីថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ៦ និង ១៥ នាទី យប់ រូបខ្លួននិង ប្តីឈ្មោះ[redacted] សន បានជិះម៉ូតូត្រឡប់មកផ្ទះ ដោយស្ពាយកាបូប ហើយលុះពេលជិតមកដល់ផ្ទះស្រាប់តែមានមនុស្សពីរនាក់ ស្ទុះចុះពីលើម៉ូតូមកទាញយកកាបូបពីខ្លួន តែរូបខ្លួនមិនព្រមឱ្យ ក៏គ្នាវាម្នាក់បានទាញយកកាំភ្លើងបាញ់ ត្រូវចំភ្លៅខាងឆ្វេងចំនួនមួយគ្រាប់ ហើយបានបាញ់បន្តទៀត ក៏បណ្តាលឲ្យត្រូវគ្នាវាម្នាក់ រួចបន្តបាញ់មកលើរូបខ្លួនទៀត ក៏ត្រូវចំដោះខាងឆ្វេងមួយគ្រាប់ ត្រូវដើមទ្រូងមួយគ្រាប់ទៀត ហើយគ្នាវាម្នាក់បានរត់គេចខ្លួនបាត់ ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិន បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ វេលាម៉ោងប្រាំមួយ និង សាមសិបនាទីយប់ រូបខ្លួន និងប្រពន្ធឈ្មោះ[redacted] សារិន បានជិះម៉ូតូត្រឡប់មកផ្ទះ ដោយស្ពាយកាបូបពណ៌ខ្មៅ រួចពេលជិះមកដល់ផ្ទះ ស្រាប់តែ មានមនុស្សពីរនាក់បាន



Scanned by CamScanner

ស្ទុះ ចូលមកដណ្ដើមទាញកាបូបពីប្រពន្ធរបស់ខ្លួន ពេលនោះប្រពន្ធរបស់ខ្លួនមិនព្រមឲ្យស្រាប់តែគ្នាវាម្នាក់បានដកយកកាំភ្លើងខ្លីបាញ់មកលើប្រពន្ធរបស់ខ្លួន ចំនួនពីរគ្រាប់ ភ្លាមនោះរូបខ្លួនក៏ប្រតាយប្រតប់ជាមួយគ្នាវាម្នាក់ទៀត រួចគ្នាវាក៏រើសយកកាំភ្លើងបាញ់សំដៅមកលើរូបខ្លួន តែមិនត្រូវបែរជាត្រូវគ្នាវាម្នាក់ដួលសន្លប់នៅកន្លែងកើតហេតុតែម្ដង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] លន បានបញ្ជាក់ថា៖ កាលពីថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ៦និង៣០ នាទីយប់ ពេលខ្លួនកំពុងអង្គុយនៅមុខផ្ទះ ស្រាប់តែឮលឺសូសំលេងផ្ទុះគ្រាប់កាំភ្លើង ចំនួនពីរគ្រាប់ រួចរូបខ្លួនក៏រត់ទៅមើល ក៏ឃើញជនជាប់ចោទម្នាក់ត្រូវគ្រាប់ដួលដេកនៅលើផ្លូវ ហើយជនរងគ្រោះឈ្មោះ [redacted] សារិន ត្រូវគ្រាប់កាំភ្លើងដួលនៅលើដី ភ្លាមនោះប្ដីរបស់ជនរងគ្រោះឈ្មោះ [redacted] សិន បានតប់ដុំថ្មមកលើជនជាប់ចោទម្នាក់ រួចក៏ប្រតាយប្រតប់គ្នា ពេលនោះវាបាញ់ពីរគ្រាប់ មួយគ្រាប់បាញ់ចុះក្រោម មួយគ្រាប់ទៀតបាញ់ឡើងលើ បានមួយស្ទុះក៏មានសមត្ថកិច្ច ចុះមកអន្តរាគមន៍ដល់កន្លែងកើតហេតុ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីលក្ខណ៍ បានបញ្ជាក់ថា៖ កាលពីថ្ងៃកើតហេតុនោះរូបខ្លួនកំពុងធ្វើម្ហូបហូបបាយ ស្រាប់តែឮស្នូរសំលេងម្ដាយរបស់ខ្លួនបានស្រែក រូបខ្លួនក៏បានរត់ចេញមកមើល ក៏ឃើញមនុស្សប្រុសពីរនាក់ ភ្លាមនោះពួកវាក៏បាញ់កាំភ្លើងជាច្រើនគ្រាប់ ហើយម្ដាយរបស់ខ្លួនបានស្រែកថា-កូនហើយជួយម៉ែផង- តែរូបខ្លួនមិនហ៊ានចេញមកទេ ព្រោះគ្នាវាម្នាក់ឈរកាន់កាំភ្លើង បានបន្តិចក៏មានអ្នកជិតខាងឆោឡោ ហើយរូបខ្លួនក៏ចេញមកជួយម្ដាយរបស់ខ្លួន អង្គុយអោបដើមទ្រូង មានចេញឈាមជោគខ្លួន បានបន្តិចក៏មានសមត្ថកិច្ចចុះមកដល់ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] មេសា បានបញ្ជាក់ថា ៖ កាលពីថ្ងៃទីកើតហេតុនោះ ពេលខ្លួនកំពុងតែអង្គុយនៅក្នុងផ្ទះ ស្រាប់តែឮស្នូរសំលេងផ្ទុះកាំភ្លើងចំនួនបីគ្រាប់ ហើយក៏បានឮគេស្រែកថាចោរៗ ពេលនោះក៏មានឈ្មោះ [redacted] សិន កំពុងប្រតាយប្រតប់ជាមួយចោរម្នាក់ទៀត ជនរងគ្រោះកំពុងអង្គុយផ្ទប់ដើមទ្រូងកុំឲ្យឈាម មួយសន្ទុះក្រោយមកក៏មានសមត្ថកិច្ចចុះដល់តែម្ដង ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការៈ ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ, អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី,អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ [redacted] គឹមឡុង និង ឈ្មោះ [redacted] តូ ពិតជាបានធ្វើសកម្មភាពដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយបានបាញ់កាំភ្លើង ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកថាជាអំពើលួច(មានស្ថានទម្ងន់) ហើយជនជាប់ចោទជានីតិជនមានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ និងមានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] គឹមឡុង ពីបទអំពើ លួច(មា នស្ថានទម្ងន់) ដែលប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១២ ដែលត្រូវបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៥២ ដក សព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង។



Scanned by CamScanner

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទៈ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, អំណានចម្លើយសាក្សី, ជនរងគ្រោះ និងដើមបណ្តឹង យល់ឃើញថាកាលពីថ្ងៃទីកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ កូនក្តីរបស់ខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសទេ គឺកូនក្តីខ្លួនជាអ្នកចូលជួយឃាត់ឈ្មោះ [redacted] តូ កុំឱ្យឈ្លោះគ្នាជាមួយជនរងគ្រោះ ប៉ុន្តែស្រាប់តែឈ្មោះ [redacted] តូ បាញ់ជនរងគ្រោះ និងកូនក្តីខ្លួនបណ្តាលឱ្យត្រូវរបួសតែម្តង។ ហេតុដូច្នេះខ្លួនស្នើសុំដល់តុលាការមេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១-ជនជាប់ចោទឈ្មោះ [redacted] គឹមឡុង ហៅ ឡុង បានឆ្លើយថាៈ កាលពីថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១២ វេលាម៉ោងប្រហែល បូនរសៀល ឈ្មោះ [redacted] តូ បានមកបបួលរូបខ្លួនឲ្យទៅទារលុយគេនៅក្រុងតាខ្មៅ។ លុះពេលមកដល់ផ្ទះជនរងគ្រោះ ឈ្មោះ [redacted] តូ បានចុះទៅនិយាយជាមួយជនរងគ្រោះ ក៏មានទំនាស់គ្នា និងប្រទាញប្រទង់គ្នា រួចខ្លួនក៏ចូលជួយឃាត់ ស្រាប់តែឈ្មោះ [redacted] តូ បានដកកាំភ្លើងបាញ់ បូនទៅប្រាំគ្រាប់ បណ្តាលឲ្យត្រូវខ្លួនចំត្រគៀកខាងឆ្វេងមួយគ្រាប់ដួលអុកគូថ ចំណែកឈ្មោះ [redacted] តូ បានរត់គេចខ្លួនបាត់ គ្រាន់តែជាចម្លើយឆ្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ មិនមានភស្តុតាងបញ្ជាក់ទេ។

២-ជនរងគ្រោះឈ្មោះ [redacted] សារិន បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃកើតហេតុ ខ្លួននិង ប្តីឈ្មោះ [redacted] សិន បានជិះម៉ូតូត្រឡប់មកផ្ទះ ដោយស្ពាយកាបូប ហើយលុះពេលជិតមកដល់ផ្ទះស្រាប់តែមានមនុស្សពីរនាក់ ស្ទុះចុះពីលើម៉ូតូមកទាញយកកាបូបពីខ្លួន តែរូបខ្លួនមិនព្រមឱ្យ ក៏គ្នាវាម្នាក់បានទាញយកកាំភ្លើងបាញ់ ត្រូវចំភ្លៅខាងឆ្វេង ចំនួនមួយគ្រាប់ ហើយបានបាញ់បន្តទៀតបណ្តាលឲ្យត្រូវគ្នាវាម្នាក់ រួចបន្តបាញ់មកលើរូបខ្លួនទៀត ក៏ត្រូវចំដោះខាងឆ្វេងមួយគ្រាប់ ត្រូវដើមទ្រូងមួយគ្រាប់ទៀត ហើយគ្នាវាម្នាក់បានរត់គេចខ្លួនបាត់ ដែលមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិន។

៣-សាក្សីឈ្មោះ [redacted] លន បានឆ្លើយមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសាក្សីឈ្មោះ [redacted] មេសា និងឈ្មោះ [redacted] ស៊ីវលក្ខណ៍ ថាៈ កាលពីយប់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ខ្លួនឮលឺសូស៊ លេងផ្ទុះគ្រាប់កាំភ្លើង រួចរូបខ្លួនក៏រត់ទៅមើល ក៏ឃើញជនជាប់ចោទម្នាក់ត្រូវគ្រាប់ដួលដេកនៅលើផ្លូវ



Scanned by CamScanner

ហើយជនរងគ្រោះឈ្មោះ [redacted] សារិន ត្រូវគ្រាប់កាំភ្លើងនៅលើដី រីឯប្ដីរបស់ជនរងគ្រោះឈ្មោះ [redacted] សិន បានប្រតាយប្រតប់ជាមួយជនជាប់ចោទ បានមួយស្នុះក៏មានសមត្ថកិច្ច ចុះមកអន្តរាគមន៍ដល់កន្លែងកើតហេតុ។

៤-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] សារិន, ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សិន ,សាក្សីឈ្មោះ [redacted]លន ,សាក្សីឈ្មោះ [redacted] មេសា និងសាក្សីឈ្មោះ[redacted] ស្រីលក្ខណ៍ អាចបញ្ជាក់បានថា កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ[redacted] គឹមឡុង ពិតជាបានចូលរួមក្នុងការប្រព្រឹត្តិសកម្មភាពអំពើលួច ដែលជាកម្មសិទ្ធិស្របច្បាប់របស់ជនរងគ្រោះឈ្មោះ [redacted] សារិន ប្រាកដមែន ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទៈ អំពើលួច (មានស្ថានទម្ងន់) តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧នៃក្រមព្រហ្មទណ្ឌ។

៥-តាមចម្លើយជនរងគ្រោះឈ្មោះ[redacted]សារិន, ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិន, សាក្សីឈ្មោះ[redacted]លន, សាក្សីឈ្មោះ[redacted] មេសា,សាក្សីឈ្មោះ [redacted] ស្រីលក្ខណ៍ និងជនជាប់ចោទឈ្មោះ [redacted]គឹមឡុង អាចបញ្ជាក់បានថា នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ជនជាប់ចោទឈ្មោះ[redacted] តូ ពិតជាបានប្រព្រឹត្តអំពើលួច (មានទម្ងន់) ទ្រព្យសម្បត្តិរបស់ជនរងគ្រោះប្រាកដមែន ប៉ុន្តែដោយឈ្មោះ[redacted] តូ មិនអាចស្វែងរកអត្តសញ្ញាណឃើញក្រោយពេលបញ្ចប់កិច្ចស៊ើបសួរ ហេតុដូច្នេះចៅក្រមស៊ើបសួរបានសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] តូ តាមដីកាដំណោះស្រាយលេខៈ ២៤០ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ រួចហើយ។

៦-អំពើរបស់ជនត្រូវចោទឈ្មោះ[redacted]គឹមឡុង បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសង្គម និងទ្រព្យសម្បត្តិ របស់បុគ្គលឯកជន ហើយជនត្រូវចោទជានីតិជន មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណាមួយបញ្ជាក់ថាជនជាប់ចោទមានបញ្ហាខាងសតិស្មារតីឡើយ។

៧-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពី ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧នៃក្រមព្រហ្មទណ្ឌ។

៨-វត្ថុតាងរួមមានៈ ម៉ូតូម៉ាកស៊ុយសូគីស្មាក់វី សេរីឆ្នាំ២០១១ ពណ៌ខ្មៅ មានស្លាកលេខៈ ភ្នំពេញ 1BI ៨៧៤៤, កូនសោរសម្រាប់បញ្ឆេះចំនួនពីរម៉ាក ស៊ុយសូគី, កូនសោរផ្ទះម៉ាក SOLEX ចំនួនមួយ, ម៉ាសបិទមុខចំនួនពីរពណ៌ខៀវ, បូកកន្ទិបចំនួនមួយពណ៌ខ្មៅ, មួកសុវត្ថិភាពចំនួនមួយពណ៌ខៀវលាយប្រផេះម៉ាក INDEX និងស្បែកជើងខ្មៅចំនួនមួយគូរពណ៌ខ្មៅម៉ាករូបក្រពើ ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ របស់តំណាងអយ្យការ គឺជាសម្ភារៈប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។



Scanned by CamScanner

៩-ជនជាប់ចោទឈ្មោះ [redacted] គឹមឡុង មិនមែនជាអ្នកបាញ់ទៅលើជនជនរងគ្រោះឱ្យរងរបួស, ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង និងមិនដែលមានសាលក្រមសម្រេចផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ ឆ្នាំមុនពេលប្រព្រឹត្តអំពើនេះ គប្បីសាលាដំបូងពិចារណាពីការព្យួរទោសសម្រាប់ជនជាប់ចោទ តាមមាត្រា១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិន បានដកពាក្យបណ្តឹងឈប់ប្តឹងទាមទារសំណងពីជនជាប់ចោទ តាមពាក្យសុំដកពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ ហេតុដូច្នេះតុលាការនឹងមិនពិចារណាពីសំណងរដ្ឋប្បវេណីទេ។

## ហេតុដូច្នេះសម្រេចសេចក្តី

១-ផ្តន្ទាទោសឈ្មោះ [redacted] គឹមឡុង ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៣ឆ្នាំ (បីឆ្នាំ) តែទោសនេះត្រូវអនុវត្តចំនួន ១ឆ្នាំ ៦ខែ (មួយឆ្នាំប្រាំមួយខែ) ទោសដែលសល់ពីនេះត្រូវព្យួរ ពីបទ៖ អំពើលួច (មានស្ថានទម្ងន់) ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-រឹបអូសវត្ថុតាងរួមមាន៖ ម៉ូតូម៉ាកស៊ុយសូគីស្មាក់វី ស៊េរីឆ្នាំ២០១១ ពណ៌ខ្មៅ មានស្លាកលេខ: ភ្នំពេញ 1BI ៨៧៨៩, កូនសោរសម្រាប់បញ្ឆេះចំនួនពីរម៉ាកស៊ុយសូគី, កូនសោរផ្ទះម៉ាក SOLEX ចំនួនមួយ, ម៉ាសបិទមុខចំនួនពីរពណ៌ខៀវ, មួកកន្តិបចំនួនមួយពណ៌ខ្មៅ, មួយសុវត្ថិភាពចំនួនមួយពណ៌ខៀវលាយប្រផេះម៉ាក INDEX និងស្បែកជើងខ្មៅចំនួនមួយគូរពណ៌ខ្មៅម៉ាករូបក្រពើ ទុកជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ ចៅក្រមក្រុមប្រឹក្សា ចៅក្រមក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted] [redacted] [redacted] [redacted]

[redacted]



Scanned by CamScanner